ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៣

# ជួយកូនលោកអ្នកឲ្យទទួលបានលទ្ធផលខ្ពស់ក្នុងការសិក្សាគណិតវិទ្យា ជាមួយកម្មវិធី ALEKS®

ជូនចំពោះមាតាបិតា៖

កូនលោកអ្នកបានចុះឈ្មោះក្នុងកម្មវិធី ALEKS ដែលជាកម្មវិធីសិក្សាតាមអ៊ិនធ័រណិត សម្រាប់ថ្នាក់ទី៣-ថ្នាក់ទី១២។ កម្មវិធី ALEKS ប្រើសំណួរ ដែលបង្កើតឡើងដោយកុំព្យូទ័រ និងសំណួរដែលអាចសម្របសម្រួលតាមចម្លើយរបស់សិស្ស ដើម្បីស្ទង់មើលចំណេះដឹងផ្នែកគណិតវិទ្យារបស់សិស្ស ហើយផ្តល់ការបង្ហាត់បង្រៀនដល់សិស្សម្នាក់ៗ ដោយយោងទៅលើ**សមត្ថភាពនៃការសិក្សា**របស់សិស្ស។ កូនលោកអ្នកអាចប្រើកម្មវិធី ALEKS នៅផ្ទះ នៅសាលា ឬ នៅកន្លែងណាដែលមានកុំព្យូទ័រ និងអ៊ិនធ័រណិត។

លោកអ្នកអាចរួមចំណែកក្នុងការសិក្សារបស់កូនលោកអ្នក ដោយជំរុញឲ្យពួកគេប្រើកម្មវិធី ALEKS នៅផ្ទះ។ កូនលោកអ្នកត្រូវចុចចូលទៅក្នុងកម្មវិធីនេះ តាមវ៉ិបសៃ www.aleks.com ដោយប្រើ ឈ្មោះ និង លេខសម្ងាត់ សម្រាប់ចុចចូល ដែលគេបានផ្តល់ឲ្យ ហើយធ្វើអ្វីៗដែលនៅលើ ALEKS Pie ដែលគេបានរៀបចំ ឲ្យត្រូវតាមសេចក្តីត្រូវការនៃការសិក្សារបស់សិស្សម្នាក់ៗ។

ដើម្បីតាមដានការរីកចម្រើនរបស់កូនលោកអ្នកក្នុងកម្មវិធី ALEKS សូមឲ្យកូនលោកអ្នកចុចចូលក្នុងកម្មវិធី ហើយចុចត្រង់បណ្តាញតភ្ជាប់ទៅរបាយការណ៍ ដែលនៅប៉ែកខាងលើនៃជ្រុងខាងស្តាំ។ លោកអ្នកនឹងឃើញរបាយការណ៍ដែលអាច ផ្លាស់ប្តូរដោយស្វ័យប្រវត្ត រៀបរាប់លម្អិតអំពីចំណេះដឹង និងប្រវត្តនៃការរីកចម្រើននាពេលបច្ចុប្បន្នរបស់កូនលោកអ្នក ក្នុងកម្មវិធី ALEKS។ លោកអ្នកក៏អាចចុចលើពាក្យ Review ដើម្បីមើលប្រធានបទដែលកូនលោកអ្នកត្រូវការរៀនសាឡើងវិញបន្ថែមទៀត។

**កម្មវិធី ALEKS គឺជាកម្មវិធីគណិតវិទ្យាតាមអ៊ិនធ័រណិត ដែលផ្អែកទៅលើការសិក្សាស្រាវជ្រាវដែលគេបានធ្វើរួចមកហើយ៖**

- សំណួរ ដែលបង្កើតឡើងដោយកុំព្យូទ័រ គឺដើម្បីបំពេញការខ្វះខាតនៃចំណេះដឹងរបស់សិស្សម្នាក់ៗ
- ចម្លើយតាមគំនិតផ្ទាល់ខ្លួន ដើម្បីចៀសវាងសំណួរដែលមានចម្លើយសម្រាប់ឲ្យជ្រើសរើស
- របាយការណ៍ស្វ័យប្រវត្ត ដើម្បីតាមដានការរីកចម្រើនរបស់សិស្ស ទៅតាមកម្រិតរបស់រដ្ឋ និងតាមខ្នាតគំរូទូទៅ
- បង្រៀនជាពីរភាសា – អង់គ្លេស និង អេស្ប៉ាញ៉ុល
- ប្រើតាមអ៊ិនធ័រណិតដោយគ្មានកំណត់ – អាចប្រើជាមួយ PC និង Mac
- តារាងដែលគេឧស្សាហ៍ប្រើ – កម្មវិធីសិក្សាគណិតវិទ្យា សម្រាប់លេខ គុណ ចែក បូក និង លេខដក

លើសពីនេះទៀត គឺធ្វើឲ្យបទពិសោធន៍នៃការសិក្សាគណិតវិទ្យា កាន់តែសប្បាយ និងកាន់តែពូកែថែមទៀត។ កម្មវិធី ALEKS អនុញ្ញាតឲ្យសិស្សានុសិស្ស រៀនតាមសមត្ថភាពរបស់ពួកគេ ដោយផ្តល់លំនាំសិក្សាច្បាស់លាស់ មានគុណភាពខ្ពស់សម្រាប់សេចក្តីត្រូវការរបស់សិស្សម្នាក់ៗ។ ការបង្ហាត់បង្រៀនសម្រាប់សិស្សម្នាក់ៗនេះ ជំរុញឲ្យមានល្បឿននៃការសិក្សា ជួយឲ្យសិស្សមានជោគជ័យ និងជឿជាក់លើសមត្ថភាពផ្នែកគណិតវិទ្យារបស់ពួកគេ។

ខ្ញុំសង្ឃឹមថា លោកអ្នកនឹងជំរុញកូនឲ្យប្រើ កម្មវិធី ALEKS នៅផ្ទះ ដើម្បីឲ្យពួកគេមានបទពិសោធន៍ក្នុងការសិក្សាគណិតវិទ្យា ដែលអាចផ្តល់លទ្ធផលខ្ពស់។ **ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីកម្មវិធី ALEKS សូមមើលវ៉ិបសៃ www.aleks.com**។

សូមឲ្យមានសំណាងល្អ

ដើម្បីជ្រាបពីឯកសារដែលបានបកប្រែ និងព័ត៌មានបន្ថែមជាភាសាខ្មែរ សូមមើលក្នុងវ៉ិបសៃ៖ www.philasd.org/language/khmer

ALEKS is a registered trademark of ALEKS Corporation.